# ការបោះឆ្នោតសហព័ន្ធអូស្ត្រាលីឆ្នាំ២០១០

ការបោះឆ្នោតសហព័ន្ធអូស្ត្រាលីឆ្នាំ ២០១០ នឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ទី21 ខែសីហា ឆ្នាំ2010 ។ លោកអ្នកអាចអញ្ជើញមកធ្វើការបោះឆ្នោតដោយផ្ទាល់នៅស្ថានទូតអូស្ត្រាលីនៅរាជធានីភ្នំពេញ ឬ ដោយការដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ (Postal Vote) ។ លោកអ្នកត្រូវតែស្គាល់អាស័យដ្ឋានស្ថានីយ៍បោះឆ្នោតអូស្ត្រាលីដែលលោកអ្នកបានចុះឈ្មោះនាពេលថ្មីៗនេះដើម្បីទទួលបាននូវសន្លឹកឆ្នោតដ៏ត្រឹមត្រូវសំរាប់ធ្វើការបោះឆ្នោត។ លោកអ្នកក៏អាចចូលទៅកាន់គេហទំព័រ (www.aec.gov.au/check) ឬទូរស័ព្ទទៅកាន់លេខ (+61 2 62714411) ។

ស្ថានទូតអូស្ត្រាលីនៅរាជធានីភ្នំពេញ នឹងរៀបចំការបោះឆ្នោតមុនគេដែលនឹងចាប់ផ្តើមពីថ្ងៃច័ន្ទ ទី9 ខែសីហា ឆ្នាំ2010 នេះតទៅ ។ ស្ថានទូតបើកបំរើការពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង 8:00ព្រឹក ដល់ម៉ោង 12:00ថ្ងៃត្រង់ និងចាប់ពីម៉ោង 1:30 រសៀល ដល់ម៉ោង 5:00ល្ងាច ហើយនៅសុក្រចាប់ពីម៉ោង 8:00ព្រឹក ដល់ម៉ោង 12:00ថ្ងៃត្រង់ និងចាប់ពីម៉ោង 1:30រសៀល ដល់ម៉ោង4:15ល្ងាច ។ ការមកបោះឆ្នោតមុនគេក្នុងអំឡុងពេលនេះគឺលោកអ្នកចៀសវាងបាននូវការរង់ចាំយូរ ឬ ការយឺតយ៉ាវបាន ។

ស្ថានទូតអូស្ត្រាលីនឹងបើកបំរើការផងដែរនៅថ្ងៃបោះឆ្នោត ចាប់ពីម៉ោង9:00ព្រឹក ដល់ម៉ោង4:00 ល្ងាច ។ ដើម្បីធានាបាននូវសន្តិសុខ សូមមេត្តាយកប័ណ្ណសំគាល់ខ្លួនរបស់លោកអ្នកមកជាមួយផង ។

ជំរើសមួយទៀត លោកអ្នកក៏អាចដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍បានផងដែរ ដោយគ្រាន់តែចូលទៅកាន់គេហទំព័រ (www.aec.gov.au) ហើយបោះពុម្ពយក និងបំពេញពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ជាការស្រេច។ លោកអ្នកក៏អាចមកកាន់ស្ថានទូតអូស្ត្រាលីដើម្បីទទួលយកនូវពាក្យសុំបោះឆ្នោតតាមប្រៃសណីផងដែរ ។ ស្ថានទូតអូស្ត្រាលីនៅរាជធានីភ្នំពេញនឹងទទួលយកពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍រហូតដល់ម៉ោង 5:00ល្ងាច ថ្ងៃព្រហស្បតិ៍ ទី19 ខែសីហា ឆ្នាំ2010 ។ ហើយសន្លឹកឆ្នោតរបស់លោកអ្នកនឹងត្រូវផ្ញើជូនទៅលោកអ្នកដើម្បីបំពេញ ហើយផ្ញើតាមប្រៃសណីយ៍ត្រលប់ទៅវិញ ។ ប្រសិនបើលោកអ្នកជ្រើសរើសយកការបោះឆ្នោតតាមប្រៃសណីយ៍នោះ ត្រូវដាក់ពាក្យសុំឥឡូវនេះ ដើម្បីអោយយើងអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ជូនសន្លឹកឆ្នោតទៅលោកអ្នកអោយបានទាន់ពេលវេលា។

ប្រសិនបើលោកអ្នកពុំអាចអញ្ជើញមកមជ្ឈមណ្ឌលបោះឆ្នោតនៅក្រៅប្រទេសណាមួយបាន ឬពុំអាចធ្វើការបោះឆ្នោតតាមប្រៃសណីយ៍បាននោះ លោកអ្នកគប្បីជូនដំណឹងទៅគណៈកម្មការរៀបចំបោះ

ឆ្នោតអូស្ត្រាលី តាមរយៈ (Email: info@aec.gov.au) ។ សំរាប់ពត៌មានបន្ថែមមាននៅក្នុងគេហទំព័រ (www.aec.gov.au) ឬទូរស័ព្ទទៅលេខៈ(+61 2 62714411) ឬ (Email: info@aec.gov.au) ៕


**ស្ថានទូតអូស្ត្រាលី**

ផ្ទះលេខ 16B ផ្លូវរដ្ឋសភា

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ 855-23 213 470 ទូរសារលេខៈ 855-23-213 413

Email: Australian.embassy.cambodia@dfat.gov.au